# កម្មវិធីលុបគំនូរលើជញ្ជាំងសាធារណៈ
# រហ័ស បែបបទយល់ព្រម និង
# ផ្តល់ការអនុញ្ញាត

(សូមបំពេញបែបបទនេះដោយអក្សរពុម្ពដែលអាចអានបាន)

**ឈ្មោះម្ចាស់អចលនទ្រព្យ៖** ______________________________

**លេខទូរស័ព្ទរបស់ម្ចាស់អចលនទ្រព្យ៖** ______________________________

**អ៊ីមែលរបស់ម្ចាស់អចលនទ្រព្យ៖** ______________________________

*ព័ត៌មានអំពីអចលនទ្រព្យ៖ រាយអាសយដ្ឋានអចលនទ្រព្យនីមួយៗ ហើយប្រើបែបបទនេះ ប្រសិនបើអ្នកមានអចលនទ្រព្យលើសពីបី ។

| គូសធីកប្រអប់ ប្រសិនបើអ្នកមានគំនូរលើជញ្ជាំងសាធារណៈនៅលើអចលនទ្រព្យរបស់អ្នក | អាសយដ្ឋានអចលនទ្រព្យ | TACOMA, WA | ហ្ស៊ីបកូដ |
|---|---|---|---|
| ☐ | | TACOMA, WA | |
| ☐ | | TACOMA, WA | |
| ☐ | | TACOMA, WA | |

ហត្ថលេខីទទួលស្គាល់ថា គាត់/នាង គឺជាម្ចាស់ ឬតំណាងដែលមានការអនុញ្ញាតពីម្ចាស់អចលនទ្រព្យខាងលើ ហើយប្រកាសថា៖

ខ្ញុំសូមស្នើ និងអនុញ្ញាឲ្យទីក្រុង Tacoma ឬអ្នកម៉ៅការរបស់ខ្លួន ដែលស្ថិតក្រោមកម្មវិធីលុបគំនូរលើជញ្ជាំងសាធារណៈរហ័ស ចូលក្នុងបរិវេណអចលនទ្រព្យរបស់ខ្ញុំ ប្រសិនបើចាំបាច់ ដើម្បីលុបគំនូរលើជញ្ជាំងសាធារណៈនៅតាមទីតាំង (ផ្សេងៗ) ដូចខាងលើ ។ ខ្ញុំយល់ ថាវាជាឆន្ទានុសិទ្ធិរបស់ក្រុង ឬអ្នកម៉ៅការរបស់ខ្លួន ក្នុងការសម្រេចថាតើវិធី ឬរបៀបអ្វីដែលត្រូវប្រើដើម្បីលុបគំនូរលើជញ្ជាំងនៃអចលនទ្រព្យរបស់ខ្ញុំ ។ ខ្ញុំសូមអះអាងថាមិនបង្កគ្រោះថ្នាក់ ហើយសូមឲ្យទីក្រុង Tacoma មន្ត្រី បុគ្គលិក ភ្នាក់ងារ អ្នកម៉ៅការ និងអ្នកស្ម័គ្រចិត្តរបស់ក្រុង រួចផុតពីការទទួលខុសត្រូវទាំងអស់ ការទារសំណង ការទាមទារ ដើមហេតុនៃបណ្តឹង ឬកាតព្វកិច្ចអ្វីក៏ដោយ ទោះដឹង ឬមិនដឹង ដោយផ្ទាល់ ឬប្រយោល ដែលកើតឡើងចេញពី ឬទាក់ទងនឹងការចូលទៅក្នុងបរិវេណអចលនទ្រព្យរបស់ខ្ញុំសម្រាប់គោលបំណងលុបគំនូរលើជញ្ជាំងសាធារណៈ ស្របតាមកម្មវិធីលុបគំនូរលើជញ្ជាំងសាធារណៈរហ័ស មានជាអាទិ៍ ការទារសំណង ឬការទាមទារទាំងអស់សម្រាប់របួសស្នាមបុគ្គល មរណភាព និងការខូចខាតអចលនទ្រព្យ រូបរាង និងស្ថានភាពរបស់អចលនទ្រព្យ ។

ខ្ញុំទទួលស្គាល់ថា ការអនុញ្ញាតនេះមានសុពលភាពចាប់ពីកាលបរិច្ឆេទចុះហត្ថលេខា រហូតដល់ថ្ងៃទី 1 ខែ មករា ឆ្នាំ 2025 ប្រសិនបើខ្ញុំមិនលក់អចលនទ្រព្យខាងលើមុនកាលបរិច្ឆេទនោះទេ ។ នៅពេលលក់ ខ្ញុំនឹងជូនដំណឹងទៅក្រុង ដើម្បីអាចទទួលបានការអនុញ្ញាតថ្មីពីម្ចាស់កម្មសិទ្ធិ ។

ក្រៅពីនេះ ខ្ញុំយល់ ថានេះជាគម្រោងមួយដែលអនុវត្តតាមឆន្ទានុសិទ្ធិរបស់ទីក្រុង Tacoma ឬអ្នកម៉ៅការរបស់ខ្លួន ។ ការទទួលបានលិខិតអនុញ្ញាតនេះ មិនជានាសេវាកម្មទេ ហើយផ្អែកលើមូលនិធិដែលមាន ។ ក្រោមក្រមសាលាក្រុង Tacoma ម្ចាស់អចលនទ្រព្យត្រូវទទួលខុសត្រូវចំពោះការលុបគំនូរលើជញ្ជាំងនៃអចនទ្រព្យរបស់ពួកគេ ។

ខ្ញុំសូមទទួលស្គាល់ថា ខ្ញុំជាម្ចាស់អចលនទ្រព្យពេញសិទ្ធិ ឬតំណាងដែលមានការអនុញ្ញាតត្រឹមត្រូវ និងសូមអះអាងទាំងស្រុងថា ព័ត៌មាននេះគឺត្រឹមត្រូវ និងពិតប្រាកដ ហើយផ្តល់ឲ្យទីក្រុង Tacoma នូវលទ្ធភាពក្នុងការអនុវត្តសំណើនេះ ។

**ឈ្មោះជាអក្សរពុម្ពធំ៖** ______________________________
ម្ចាស់អចលនទ្រព្យ ឬតំណាងដែលមានការអនុញ្ញាត

**ហត្ថលេខា៖** ______________________________ **កាលបរិច្ឆេទ៖** ______________
ម្ចាស់អចលនទ្រព្យ ឬតំណាងដែលមានការអនុញ្ញាត

សូមបំពេញ ហើយអ៊ីមែលបែបបទសុំការអនុញ្ញាតនេះទៅ graffiti@cityoftacoma.org
*មានតែអចលនទ្រព្យនៅក្នុងទីក្រុង Tacoma ប៉ុណ្ណោះ នឹងត្រូវបានពិចារណាឲ្យចូលរួមក្នុងកម្មវិធីនេះ ។